**វិទ្យាស្ថានសភាកម្ពុជា**
**PARLIAMENTARY INSTITUTE OF CAMBODIA**

## ឯកសារស្រាវជ្រាវ

### គណៈកម្មការទី១០ នៃព្រឹទ្ធសភា

# ទំនាក់ទំនងរវាងការប្រឆាំងអំពើពុករលួយ និង ដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ៖ សាធារណរដ្ឋប្រជាមានិតចិន និងប្រទេសអូស្ត្រាលី

ខែមីនា ឆ្នាំ២០១៧


អ្នកស្រាវជ្រាវ៖ **កញ្ញា ជា សុគន្ធមិនា**
សហការីស្រាវជ្រាវ៖ **កញ្ញា ហេង នីដា**
**លោកស្រី វ៉ាន់ ណារី**

# កំណត់សម្គាល់

វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក) គឺជាស្ថាប័នឯករាជ្យមួយ ដែលផ្តល់ការគាំទ្រដល់សភាកម្ពុជា តាមរយៈការផ្តល់នូវឯកសារស្រាវជ្រាវទៅតាមសំណើរបស់សមាជិក-សមាជិកា និងគណៈកម្មការជំនាញរបស់រដ្ឋសភា-ព្រឹទ្ធសភា ដែលមានការវិភាគទៅលើបញ្ហា ដែលកំពុងតែកើតមាននៅពេលបច្ចុប្បន្ន និងដែលអាចនឹងកើតឡើងនាពេលអនាគតលើប្រធានបទការរៀបចំច្បាប់ និងគោល-នយោបាយសាធារណៈ។ ឯកសារទាំងនេះផ្តល់នូវព័ត៌មានផ្សេងៗ ដែលពាក់ព័ន្ធនឹងការងារសភា និងការងារមណ្ឌល ឬភូមិភាគរបស់សមាជិក-សមាជិការសភា ក៏ប៉ុន្តែរាល់អត្ថន័យដែលមាននៅក្នុងឯក-សារទាំងនេះមិនមែនតំណាងឬឆ្លុះបញ្ចាំងអំពីទស្សនៈផ្ទាល់របស់វិទ្យាស្ថានសភាកម្ពុជាសភា ឬសមាជិក-សមាជិកាណាម្នាក់នោះឡើយ។

ខ្លឹមសារនៃឯកសារទាំងនេះ មានកំណត់នូវកាលបរិច្ឆេទរៀបចំច្បាស់លាស់ និងអាចប្រើប្រាស់សម្រាប់តែជាឯកសារយោងប៉ុណ្ណោះ។ ឯកសារទាំងនេះមិនមានគោលបំណងផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬទៅលើគោលនយោបាយណាមួយឡើយ ហើយក៏មិនបានធ្វើការសិក្សាអោយបានគ្រប់ប្រធានបទ ឬរាល់ខ្លឹមសារលម្អិតដែលពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងនោះដែរ។

ខ្លឹមសារនៃឯកសារស្រាវជ្រាវនេះ ស្ថិតក្រោមច្បាប់ជាធរមានរបស់កម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិអ្នកនិពន្ធ។ រាល់ការរៀបចំឡើងវិញដោយដកស្រង់នូវផ្នែកណាមួយ ឬខ្លឹមសារទាំងស្រុងនៃឯកសារស្រាវជ្រាវនេះ ត្រូវមានការអនុញ្ញាតពីវិទ្យាស្ថាន។

© រក្សាសិទ្ធិ ឆ្នាំ ២០១៧ វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក) ។

# មាតិកា


សេចក្ដីសង្ខេប ..... 1

១. សេចក្ដីផ្ដើម ..... 2

២.សាធារណរដ្ឋប្រជាមានិតចិន ..... 3

២.១. ស្ថានភាពបច្ចុប្បន្ននៃការប្រឆាំងអំពើពុករលួយ និងប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ នៅប្រទេសចិន ..... 3

២.១.១. ការប្រឆាំងអំពើពុករលួយ ..... 3

២.១.២. ប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ ..... 5

២.២. បញ្ហាប្រឈមចំពោះដំណើរការប្រឆាំងអំពើពុករលួយ ..... 8

២.៣. ក្របខ័ណ្ឌច្បាប់ និងយន្តការប្រឆាំងអំពើពុករលួយ ..... 9

២.៤. ទំនាក់ទំនងរវាងប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ និងដំណើរការប្រឆាំងអំពើពុករលួយ ..... 11

៣. ប្រទេសអូស្ត្រាលី ..... 12

៣.១. ស្ថានភាពបច្ចុប្បន្ននៃការប្រឆាំងអំពើពុករលួយ និងប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ នៅប្រទេសអូស្ត្រាលី ..... 12

៣.១.១. ការប្រឆាំងអំពើពុករលួយ ..... 12

៣.១.២. ប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ ..... 14

៣.២. បញ្ហាប្រឈមចំពោះដំណើរការប្រឆាំងអំពើពុករលួយ ..... 17

៣.៣. ក្របខ័ណ្ឌច្បាប់ និងយន្តការក្នុងការប្រឆាំងអំពើពុករលួយ ..... 18

៣.៤. ទំនាក់ទំនងរវាងប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ និងដំណើរការប្រឆាំងអំពើពុករលួយ ..... 20

៤. សេចក្ដីសន្និដ្ឋាន ..... 21

# សេចក្តីសង្ខេប

ប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ គឺជាប្រព័ន្ធដែលប្រទេសជាច្រើន បាននឹងកំពុងអនុវត្ត ដោយសារប្រព័ន្ធនេះ ត្រូវបានចាត់ទុកជាប្រព័ន្ធអភិបាលកិច្ចមួយដ៏ល្អ ដែលអាចផ្តល់សេវាសាធារណៈកាន់តែល្អប្រសើរដល់ប្រជាពលរដ្ឋមូលដ្ឋាន។ លើសពីនេះទៅទៀត ប្រព័ន្ធនេះ ក៏រួមចំណែកយ៉ាងទូលំទូលាយចំពោះការប្រឆាំងអំពើពុករលួយផងដែរ។

ស្រដៀងគ្នាទៅនឹងប្រទេសដទៃទៀតដែរនោះ ប្រទេសចិន និងប្រទេសអូស្ត្រាលី ព្យាយាមទប់ស្កាត់អំពើពុករលួយ តាមរយៈការបង្កើតភ្នាក់ងារប្រឆាំងអំពើពុករលួយ ក៏ដូចជាក្របខ័ណ្ឌច្បាប់នានា។ ប្រទេសទាំងពីរ ប្រើប្រាស់ច្បាប់ព្រហ្មទណ្ឌជាគោល ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ។ ខណៈពេលដែលប្រទេសអូស្ត្រាលី មានច្បាប់ប្រឆាំងអំពើពុករលួយគ្រប់គ្រាន់ ប្រទេសចិន ទើបតែបានអនុម័តបទប្បញ្ញត្តិមួយចំនួន តាមរយៈយុទ្ធនាការប្រឆាំងអំពើពុករលួយ។ ទោះបីជាយ៉ាងនេះក្តី បញ្ហាប្រឈមនៅតែកើតមាន ចំពោះដំណើរការប្រឆាំងអំពើពុករលួយ នៅក្នុងប្រទេសចិន និងប្រទេសអូស្ត្រាលី។ ឥទ្ធិពលនយោបាយទៅលើការស៊ើបអង្កេតអំពើពុករលួយ ហាក់ដូចជាចោទជាបញ្ហាចម្បង ចំពោះប្រទេសចិន។ ចំណែកឯប្រទេសអូស្ត្រាលីវិញ សិទ្ធិអំណាចរបស់ភ្នាក់ងារប្រឆាំងអំពើពុករលួយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គឺមានលក្ខណៈមិនស្របគ្នា ដែលធ្វើឲ្យរាំងស្ទះ ចំពោះដំណើរការប្រឆាំងអំពើពុករលួយ។

ដោយសារប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ ត្រូវបានរំពឹងទុកជាគំរូអភិបាលកិច្ចដ៏ល្អ ប្រទេសទាំងពីរបានប្រើប្រាស់ប្រព័ន្ធនេះ ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ។ ទោះជាយ៉ាងណា ការអនុវត្តយន្តការប្រឆាំងអំពើពុករលួយ តាមរយៈប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ មិនមែនជាការងាយស្រួលនោះទេ ហើយបញ្ហាប្រឈមមួយចំនួន នៅតែកើតមាន ជាពិសេស នៅថ្នាក់មូលដ្ឋាន។ ជាឧទាហរណ៍ អាជ្ញាធរមូលដ្ឋាននៅប្រទេសចិន ធ្វើការស៊ើបអង្កេតអំពើពុករលួយ តែនៅពេលដែលមានសេចក្តីរាយការណ៍ពីគណបក្សនយោបាយប៉ុណ្ណោះ ចំណែកឯភ្នាក់ងារប្រឆាំង អំពើពុករលួយ នៅក្នុងប្រទេសអូស្ត្រាលីមួយចំនួន មិនមានអំណាចកាត់ទោសជនដែលបានសូកប៉ាន់ឡើយ។ ដូច្នេះ ប្រទេសទាំងពីរ នៅតែជួបប្រទះនឹងការលំបាក ដើម្បីទទួលបានជោគជ័យក្នុងការប្រឆាំងអំពើពុករលួយ។

## ១. សេចក្ដីផ្ដើម

ប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ ត្រូវបានចាត់ទុកជាឧបករណ៍មួយដ៏សំខាន់ ក្នុងការពង្រឹងអភិបាលកិច្ចល្អ នៅក្នុងប្រទេសជាច្រើន ជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។[1] ខណៈពេលដែល ប្រព័ន្ធ វិមជ្ឈការ និងវិសហមជ្ឈការ អាចឲ្យអាជ្ញាធរមូលដ្ឋាន ផ្ដល់សេវាសាធារណៈកាន់តែល្អប្រសើរ ដល់ប្រជាពលរដ្ឋមូលដ្ឋាន ប្រព័ន្ធនេះ ក៏ដើរតួនាទីយ៉ាងសំខាន់ ក្នុងកិច្ចខិតខំប្រឹងប្រែងប្រឆាំងនឹងអំពើពុករលួយផងដែរ។[1] ឧទាហរណ៍ ប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ រួមចំណែកប្រឆាំងអំពើពុករលួយ តាមរយៈការកាត់បន្ថយការិយាធិបតេយ្យ ដែលអាចបង្កឲ្យមានមន្ត្រីប្រព្រឹត្តអំពើពុករលួយ។[1] លើសពីនេះទៀត សាធារណរដ្ឋប្រជាមានិតចិន និងប្រទេសអូស្ត្រាលី បានអនុវត្តយុទ្ធសាស្ត្រប្រឆាំងអំពើពុករលួយ និងបានបង្កើតភ្នាក់ងារប្រឆាំងអំពើពុករលួយ ស្របជាមួយនឹងការអនុវត្តប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការនេះនៅក្នុងប្រទេសរបស់ខ្លួន។

ឯកសារស្រាវជ្រាវនេះ នឹងផ្ដល់ការសិក្សាប្រៀបធៀបទៅលើដំណើរការប្រឆាំងអំពើពុករលួយ នៅប្រទេសចិន និងប្រទេសអូស្ត្រាលី ក្របខ័ណ្ឌច្បាប់ និងយន្តការក្នុងការប្រឆាំងអំពើពុករលួយ ព្រមទាំងទំនាក់ទំនងរវាងប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ និងការប្រឆាំងអំពើពុករលួយ នៅក្នុងប្រទេសទាំងពីរនេះ។ ឯកសារនេះ ត្រូវបានរៀបចំឡើងតាមករណីសិក្សាទៅលើប្រទេសចំនួនពីរ គឺប្រទេសចិន និងប្រទេសអូស្ត្រាលី។ តាមរយៈការវិភាគទៅលើឯកសារដែលមានស្រាប់ ឯកសារស្រាវជ្រាវនេះ ឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវសំខាន់ៗ ដូចខាងក្រោម៖

១. តើស្ថានភាពបច្ចុប្បន្ននៃការប្រឆាំងអំពើពុករលួយ និងប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ នៅប្រទេសចិន និងប្រទេសអូស្ត្រាលី មានលក្ខណៈយ៉ាងដូចម្ដេច?

២. តើបញ្ហាប្រឈម ចំពោះកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ នៅប្រទេសចិន និងប្រទេសអូស្ត្រាលី មានអ្វីខ្លះ?

៣. តើក្របខ័ណ្ឌច្បាប់ និងយន្តការ ដែលបានបង្កើតឡើង ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ នៅប្រទេសចិន និងប្រទេសអូស្ត្រាលី មានអ្វីខ្លះ?

៤. តើប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ មានទំនាក់ទំនងយ៉ាងដូចម្ដេច ចំពោះដំណើរការនៃកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ នៅប្រទេសចិន និងប្រទេសអូស្ត្រាលី?

## ២.សាធារណរដ្ឋប្រជាមានិតចិន

### *២.១. ស្ថានភាពបច្ចុប្បន្ននៃការប្រឆាំងអំពើពុករលួយ និងប្រព័ន្ធទីបជ្ជការ និងទីសហបជ្ជការ នៅប្រទេសចិន*

### *២.១.១. ការប្រឆាំងអំពើពុករលួយ*

- *អំពើពុករលួយ*

រយៈពេលជាង៣០ឆ្នាំមកនេះ ប្រទេសចិន ជាប្រទេស ដែលមានសេដ្ឋកិច្ចរីកលូតលាស់ យ៉ាងឆាប់-រហ័ស។[2] ទោះបីជាយ៉ាងនេះក្ដី ប្រទេសនេះ មានអំពើពុករលួយខ្ពស់ (សូមមើលរូបភាពទី១ខាង-ក្រោម)។[2] និយមន័យទូទៅនៃអំពើពុករលួយ គឺជា *«ការប្រើប្រាស់ការិយាល័យសាធារណៈ ដើម្បីផលប្រយោជន៍ឯកជន»*។[3] ទោះជាយ៉ាងណាក៏ដោយ យោងតាមឯកសារស្ដីពីភាពខ្លាំងក្លានៃអំពើពុករលួយនៅប្រទេសចិន (Intensification of Corruption in China) ដោយលោក Andrew Wedeman ឆ្នាំ២០០៤ ប្រទេសចិន បានកំណត់និយមន័យនៃអំពើពុករលួយ ជា *«ឥរិយាបថមិនត្រឹមត្រូវណាមួយរបស់មន្ត្រីរដ្ឋការ ឬសមាជិកបក្សកុម្មុយនិស្ត»*។[4]

ចាប់តាំងពីការបង្កើត «ប្រទេសចិនថ្មី (New China)» (សាធារណរដ្ឋប្រជាមានិតចិន) ក្នុងឆ្នាំ ១៩៤៩ អំពើពុករលួយ ជាបញ្ហាមួយដ៏ធ្ងន់ធ្ងររបស់ប្រទេសនេះ។[5] ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងពីសំណាក់រដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយក៏ដោយ ក៏អំពើពុករលួយ បានរីករាលដាលនៅក្នុងគ្រប់កម្រិតនៃប្រព័ន្ធនយោបាយរបស់ប្រទេសចិន ចាប់តាំងពីការធ្វើកំណែទម្រង់សេដ្ឋកិច្ច នៅក្នុងឆ្នាំ១៩៧៨។[5] លើសពីនេះទៀត ការប្រព្រឹត្តអំពើពុករលួយ ក៏កើតមានឡើង ក្នុងរូបភាពជាការសូកប៉ាន់ រវាងសហគ្រាសអាជីវកម្ម និងមន្ត្រីរដ្ឋាភិបាល[a]ផងដែរ។[5] ម្យ៉ាងទៀត អំពើពុករលួយ ហាក់ដូចជាធ្វើឲ្យកំណើនសេដ្ឋកិច្ចរបស់ប្រទេសចិន មានការធ្លាក់ចុះ ដែលធ្លាក់មកនៅត្រឹមតែចំនួនប្រមាណ៧.៥%ប៉ុណ្ណោះ នៅក្នុងឆ្នាំ២០១៥។[2]

ដូចដែលបានបង្ហាញនៅក្នុងរូបភាពទី១ខាងក្រោម យោងតាមអង្គការតម្លាភាពអន្តរជាតិ (Transparency International Organization) នៅក្នុងឆ្នាំ២០១៥ ប្រទេសចិន ទទួលបាន៣៧ពិន្ទុ នៃ១០០ពិន្ទុ (០ពិន្ទុ = ប្រជាពលរដ្ឋ យល់ឃើញថាមានអំពើពុករលួយខ្ពស់, ១០០ពិន្ទុ = ប្រជាពលរដ្ឋ យល់ឃើញថាគ្មានអំពើពុករលួយ)។ ពិន្ទុនេះ បានកើនឡើងបន្តិច ដល់ប្រមាណជា៤០ពិន្ទុ នៅក្នុងឆ្នាំ២០១៦។ នេះបង្ហាញឲ្យឃើញថា អំពើពុករលួយនៅក្នុងប្រទេសចិន នឹងនៅតែខ្ពស់ ទោះបីជាមានកិច្ចខិតខំ

[a] ឧទាហរណ៍ មន្ត្រីរដ្ឋាភិបាលម្នាក់ ដែលបម្រើការនៅក្រសួងពាណិជ្ជកម្ម ទទួលការចោទប្រកាន់ពីបទប្រព្រឹត្តអំពើពុក-លួយ នៅក្នុងការអនុញ្ញាតការវិនិយោគបរទេស ដូច្នេះមន្ត្រីម្នាក់នោះ ត្រូវបានចាប់ខ្លួននៅក្នុងឆ្នាំ២០០៨។

ប្រឹងប្រែងប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ដូចជាការបង្កើត និងអនុវត្តច្បាប់ប្រឆាំងអំពើពុករលួយ និងការរៀបចំយុទ្ធនាការប្រឆាំងអំពើពុករលួយថ្មីៗនេះក៏ដោយ។

**រូបភាពទី១៖ ការប្រៀបធៀបសន្ទស្សន៍នៃការយល់ឃើញអំពើពុករលួយនៅក្នុងប្រទេសចិន ប្រទេសអូស្ត្រាលី ប្រទេសដាណឺម៉ាក និងប្រទេសសូម៉ាលី នៅក្នុងឆ្នាំ២០១២-២០១៦[6]**




**ប្រភព៖ អង្គការតម្លាភាពអន្តរជាតិ (Transparency International Organization)**

❖ *យន្តការប្រឆាំងអំពើពុករលួយ*

បច្ចុប្បន្ននេះ ភ្នាក់ងារស៊ើបអង្កេត និងប្រឆាំងអំពើពុករលួយ នៅប្រទេសចិន មានចំនួន៤ស្ថាប័ន ដែលក្នុងនោះរួមមាន (១) អង្គភាពស៊ើបអង្កេតថ្នាក់តំបន់ (the Regional People's Procuratorates), (២) ការិយាល័យអង្កេត (Supervisory Bureaus), (៣) ការិយាល័យមូលបត្រសាធារណៈ (the Public Security Bureau) និង(៤) គណៈកម្មាធិការអធិការកិច្ចវិន័យ (Discipline Inspection Committees)។[7] គណៈកម្មាធិការអធិការកិច្ចវិន័យ (Discipline Inspection Committees) ត្រូវបានបង្កើតឡើងដោយបក្សកុម្មុយនីស្តចិន (the Communist Party of China) ដែលគណៈកម្មាធិការទាំងនេះ ទទួលបន្ទុកស៊ើបអង្កេតសកម្មភាពរបស់សមាជិកបក្ស ថាបានរំលោភបំពានបទប្បញ្ញត្តិ គណបក្ស

ដែរឬទេ។[7] តួនាទីសំខាន់របស់ភ្នាក់ងាររដ្ឋាភិបាលទាំងបីផ្សេងទៀត ដែលមានសិទ្ធិអំណាចស៊ើបអង្កេតអំពើពុករលួយ មានដូចខាងក្រោម៖[7]

- ការិយាល័យអង្កេត (Supervisory Bureaus) ផ្អែកលើបទដ្ឋាន និងបទប្បញ្ញត្តិរដ្ឋបាល ត្រួតពិនិត្យសកម្មភាពរបស់មន្ត្រីរដ្ឋាភិបាល និងមន្ត្រីមុខងារសាធារណៈ [b] (public functionaries)។[7]
- ការិយាល័យមូលបត្រសាធារណៈ (the Public Security Bureau) ស៊ើបអង្កេតអំពើពុក-រលួយ និងការសូកប៉ាន់ ក្នុងដំណើរការពាណិជ្ជកម្ម។[7]
- អង្គភាពស៊ើបអង្កេតថ្នាក់តំបន់ (the Regional People's Procuratorates) ស៊ើបអង្កេតការកេងបន្លំថវិកា (embezzlement) អចលនទ្រព្យជាតិ និងការសូកប៉ាន់របស់មន្ត្រីរដ្ឋាភិបាល និងមន្ត្រីមុខងារសាធារណៈ (public functionaries)។ អង្គភាពស៊ើបអង្កេតថ្នាក់តំបន់ (the Regional People's Procuratorates) ជាភ្នាក់ងារតែមួយគត់ ដែលមានសិទ្ធិអំណាចបង្កើតនីតិវិធីច្បាប់។ ដូច្នេះ រាល់ការស៊ើបអង្កេត ដែលធ្វើឡើងដោយការិយាល័យអង្កេត (Supervisory Bureaus) និងការិយាល័យមូលបត្រសាធារណៈ (the Public Security Bureau) ត្រូវបញ្ជូនទៅអង្គភាពស៊ើបអង្កេតថ្នាក់តំបន់ (the Regional People's Procuratorates) ប្រសិនបើមានភ័ស្តុតាងគ្រប់គ្រាន់សម្រាប់ធ្វើការផ្តន្ទាទោស។[7]

### ២.១.២. ប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ

ខណៈពេលដែលប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ រួមបញ្ចូលនូវការផ្ទេរសិទ្ធិអំណាចផ្នែកសារពើពន្ធ ផ្នែករដ្ឋបាល និងផ្នែកនយោបាយ[8] ប៉ុន្តែប្រទេសចិន ធ្វើវិមជ្ឈការតែផ្នែកសារពើពន្ធប៉ុណ្ណោះ ចំណែកឯផ្នែកនយោបាយ គឺនៅតែមជ្ឈការ។[9] យ៉ាងណាមិញ ប្រព័ន្ធនេះ អាចឲ្យអាជ្ញាធរមូលដ្ឋានធ្វើការសម្រេចចិត្ត សំខាន់ៗ ពាក់ព័ន្ធនឹងការរឹតបន្តឹងការអនុវត្តច្បាប់ដែលបានអនុម័តរួច ក៏ដូចជាធ្វើការសម្រេចចិត្តពាក់ព័ន្ធនឹងអាទិភាពនៃបទបញ្ជា (mandates)[c] ដើម្បីសម្រេចបាននូវលទ្ធផលជាក់លាក់។[9]

---

[b] យោងតាមឯកសារស្តីពីសេចក្តីណែនាំស្តីពីបទប្បញ្ញត្តិប្រឆាំងអំពើពុករលួយនៅក្នុងតំបន់អាស៊ី ដោយលោក Herbert Smith, LLP ឆ្នាំ២០១១ «មន្ត្រីមុខងារសាធារណៈ ជាបុគ្គល ដែល (i) បម្រើសេវាសាធារណៈនៅក្នុងស្ថាប័នរដ្ឋ, (ii) បម្រើសេវាសាធារណៈនៅក្នុងក្រុមហ៊ុន ឬសហគ្រាស ដែលជាកម្មសិទ្ធិរបស់រដ្ឋ, (iii) ត្រូវបានតែងតាំង ដោយក្រុមហ៊ុនដែលជាកម្មសិទ្ធិរបស់រដ្ឋ ឲ្យបម្រើសេវាសាធារណៈនៅក្នុងក្រុមហ៊ុន ឬសហគ្រាស ដែលមិនមែនជាកម្មសិទ្ធិរបស់រដ្ឋ ឬ (iv) បម្រើសេវាសាធារណៈ ដោយយោងតាមច្បាប់»។

[c] បទបញ្ជា (mandates) សំដៅទៅលើបទបញ្ជាជាផ្លូវការពីរដ្ឋាភិបាលថ្នាក់ជាតិ។

កត្តានេះ ហាក់បីដូចជាជួយធានានូវការសម្រេចគោលដៅជាតិ ដោយសារមន្ត្រីថ្នាក់មូលដ្ឋាន ដឹងច្បាស់ពីតម្រូវការ របស់ប្រជាពលរដ្ឋមូលដ្ឋាន។[9]

**រូបភាពទី២៖ រចនាសម្ព័ន្ធរដ្ឋាភិបាលប្រទេសចិន[10]**




**ប្រភព៖ កំណត់ត្រាសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** (Annals of Economics and Finance in Chunli, S., Jing, J., & Heng-fu, Z. 2012. Fiscal Decentralization in China: History, Impact, Challenges and Next Steps. p. 2)

អាជ្ញាធរមូលដ្ឋាន (សូមមើលរូបភាពទី២ខាងលើ) ត្រូវបានផ្តល់សិទ្ធិអំណាចឲ្យប្រមូលពន្ធ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ បន្ទាប់ពីមានការខ្វែងគំនិតគ្នារវាងរដ្ឋាភិបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់-មូលដ្ឋាន ពាក់ព័ន្ធនឹងការបែងចែកពន្ធ ប្រព័ន្ធបែងចែកពន្ធ (tax-sharing system) ត្រូវបានធ្វើការ កែទម្រង់ ចាប់តាំងពីឆ្នាំ១៩៩៤។[10] ជាលទ្ធផល ពន្ធនៅក្នុងប្រទេសចិន ត្រូវបានបែងចែកជាបីប្រភេទ ដូចជាពន្ធថ្នាក់ជាតិ (central taxes) ពន្ធបែងចែក (shared taxes) និងពន្ធថ្នាក់មូលដ្ឋាន (local taxes) (សូមមើលតារាងទី១ខាងក្រោម)។[10] ទោះជាយ៉ាងណា ថ្នាក់មូលដ្ឋាន នៅតែប្រឈមនឹងវិបត្តិហិរញ្ញវត្ថុ ដែលមូលហេតុចម្បងគឺដោយសារតែបំណុល ដូចបានចង្អុលបង្ហាញនៅក្នុងរបាយការណ៍ ស្តីពីស្ថានភាព និងគោលនយោបាយសារពើពន្ធរបស់ប្រទេសចិន (China's Fiscal Position and Policy)។[11] នេះគឺដោយសារតែ ស្ថានភាពហិរញ្ញវត្ថុរបស់រដ្ឋបាលមូលដ្ឋាន ពឹងផ្អែកទៅលើដី និងអចលនទ្រព្យជាតិ ក្រៅពីប្រាក់ចំណូលដែលទទួលបានពីពន្ធមូលដ្ឋាន ហើយនៅពេលដែលតម្លៃអចលនទ្រព្យជាតិ ក៏ដូចជាកិច្ចព្រមព្រៀងអាជីវកម្មដី មិនស្ថិតស្ថេរ រដ្ឋបាលមូលដ្ឋាន បានជួបប្រទះនូវបញ្ហាហិរញ្ញវត្ថុនេះ។

## តារាងទី១៖ ប្រភេទពន្ធនៅក្នុងប្រទេសចិន[11]

| ពន្ធ | ថ្នាក់ជាតិ (%) | ថ្នាក់មូលដ្ឋាន (%) |
|---|---|---|
| **ពន្ធថ្នាក់ជាតិ (Central tax)** | | |
| ពន្ធនាំចូល (Tariffs) | ១០០ | ០ |
| ពន្ធលើការប្រើប្រាស់ (Consumption tax) | ១០០ | ០ |
| **ពន្ធបែងចែក (Shared tax)** | | |
| ពន្ធលើតម្លៃបន្ថែម (VAT) | ៧៥ | ២៥ |
| ពន្ធអាជីវកម្ម (Business tax) | ៣ | ៩៧ |
| ពន្ធតែមលើការផ្លាស់ប្តូរមូលបត្រ (Stamp tax on security exchange) | ៩៧ | ៣ |
| ពន្ធលើប្រាក់ចំណូលផ្ទាល់ខ្លួន (Personal income tax) | ៦០ | ៤០ |
| ពន្ធលើប្រាក់ចំណូលក្រុមហ៊ុន (Company income tax) | ៦០ | ៤០ |
| **ពន្ធថ្នាក់មូលដ្ឋាន (Local tax)** | | |
| ពន្ធលើធនធាន (Resource tax) | ០ | ១០០ |
| ពន្ធលើការថែរក្សា និងអភិវឌ្ឍន៍ទីក្រុង (Urban maintenance and development tax) | ០ | ១០០ |
| ពន្ធលើការប្រើប្រាស់ដីទីក្រុង (Urban land using tax) | ០ | ១០០ |
| ពន្ធលើកសិកម្ម និងសកម្មភាពពាក់ព័ន្ធ (Agriculture and related tax) | ០ | ១០០ |
| ពន្ធលើកិច្ចសន្យា (Tax on contracts) | ០ | ១០០ |
| ពន្ធលើការប្រើប្រាស់ដីបង្កបង្កើនផល (Tax on the use of arable land) | ០ | ១០០ |
| | ០ | ១០០ |

| | | |
|---|---|---|
| ពន្ធលើការទិញយានយន្ត (Vehicle purchasing tax)<br>ពន្ធមូលដ្ឋានដទៃទៀត (Other local taxes) | 0 | ១០០ |

**ប្រភព៖ កំណត់ត្រាសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (Annals of Economics and Finance in Chunli, S., Jing, J., & Heng-fu, Z. 2012. Fiscal Decentralization in China: History, Impact, Challenges and Next Steps. p. 2)**

## ២.២. បញ្ហាប្រឈមចំពោះដំណើរការប្រឆាំងអំពើពុករលួយ

ការប្រឆាំងអំពើពុករលួយនៅក្នុងប្រទេសចិន ប្រឈមនឹងបញ្ហាមួយចំនួន ដូចខាងក្រោម៖

- **ឥទ្ធិពលនយោបាយ៖** អំពើពុករលួយនៅក្នុងប្រទេសចិន មានសន្ទុស្សន៍ខ្ពស់ ប៉ុន្តែដំណើរការនៃការប្រឆាំងអំពើពុករលួយ នៅតែមិនទាន់មានប្រសិទ្ធភាព។[2] សេចក្តីរាយការណ៍ថ្មីៗនេះ បានបញ្ជាក់ឲ្យដឹងថា ចាប់តាំងពីឆ្នាំ២០១២ មន្ត្រីរដ្ឋាភិបាល ដែលកាន់មុខតំណែងខ្ពស់ មិនតិចជាង១០០នាក់ ត្រូវបានផ្តន្ទាទោស។[12] ទោះយ៉ាងណាក៏ដោយ ចំនួននេះ គឺត្រូវបានប៉ាន់ប្រមាណថាប្រហែលជា៣%ប៉ុណ្ណោះ នៃចំនួនមន្ត្រីពុករលួយសរុប។[2] លើសពីនេះទៅទៀត រដ្ឋាភិបាល ក៏ប្រហែលជាអាចចូលរួមក្នុងការស៊ើបអង្កេត[2] និងអាចបង្អាក់ការស៊ើបអង្កេតយ៉ាងហ្មត់ចត់របស់ភ្នាក់ងារប្រឆាំងអំពើពុករលួយ។[2]
- **ការចំណាយ និងអំពើពុករលួយផ្ទៃក្នុង៖** ដំណើរការនៃការប្រឆាំងអំពើពុករលួយ ត្រូវចំណាយច្រើន[2] និងមានការលំបាក ដោយសារមន្ត្រីពុករលួយជាច្រើននាក់[d] កំពុងបម្រើការនៅក្នុងស្ថាប័នរដ្ឋាភិបាល ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ហើយក៏អាចទៅរួចផងដែរ ដែលពួកគេក៏កំពុងបម្រើការ នៅក្នុងភ្នាក់ងារប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ។[2]
- **កង្វះខាតទិន្នន័យ៖** គួរឲ្យកត់សម្គាល់ផងដែរថា រដ្ឋាភិបាលប្រទេសចិន ចាត់ទុកការយល់ដឹងរបស់ប្រជាពលរដ្ឋស្តីពីអំពើពុករលួយ ជាកត្តាសំខាន់ នៅក្នុងដំណើរការប្រឆាំងអំពើពុករលួយ។[3] ដូច្នេះ ព័ត៌មានពាក់ព័ន្ធនឹងករណីប្រព្រឹត្តអំពើពុករលួយ និងការផ្តន្ទាទោសតាមផ្លូវច្បាប់ ត្រូវបានទាមទារឲ្យមានការផ្សព្វផ្សាយយ៉ាងទូលំទូលាយ ដើម្បីឲ្យប្រជាពលរដ្ឋ អាចចូលរួមយ៉ាងពេញលេញនៅក្នុងដំណើរការប្រឆាំងអំពើពុករលួយនេះ[3] ប៉ុន្តែខេត្តមួយចំនួន មិនបានបង្ហាញទិន្នន័យសំខាន់នេះ ជាសាធារណៈឡើយ។[3]

[d] សុភាសិតមួយឃ្លា ដែលមន្ត្រីរដ្ឋាភិបាលតែងតែប្រើប្រាស់ គឺ «ស៊ីស្ងាត់ យកដោយសុភាព ធ្វើការដោយសម្ងាត់ (eat quietly, take gently, and play secretly)»

- **ការរិះគន់៖** ការដឹកនាំរបស់អ្នកនយោបាយ ដើរតួនាទីយ៉ាងសំខាន់ក្នុងការប្រឆាំងអំពើ- ពុករលួយដែរ។ នាពេលបច្ចុប្បន្ននេះ លោកប្រធានាធិបតី Xi Jinping បាននឹងកំពុងអនុវត្តយុទ្ធនាការប្រឆាំងអំពើពុករលួយ ចាប់តាំងពីឆ្នាំ២០១៣ ដោយក្នុងនោះមន្ត្រីរដ្ឋាភិបាលជាច្រើននាក់ កំពុងត្រូវបានត្រួតពិនិត្យ និងផ្តន្ទាទោស។[13] យ៉ាងណាមិញ សាធារណជន មន្ត្រី រដ្ឋាភិបាល ដែលទទួលរងនូវការចោទប្រកាន់ពីបទអំពើពុករលួយ និងសហគ្រាសអាជីវកម្មធំៗជាច្រើន បានរិះគន់យុទ្ធនាការនេះ ដោយសារពួកគេ ជឿជាក់ថា នេះគឺជាយុទ្ធសាស្ត្រកម្ចាត់សត្រូវរបស់លោកប្រធានាធិបតី ជាជាងវិធីសាស្ត្រប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ នៅក្នុងប្រទេសចិន។[13]

## ២.៣. ក្របខ័ណ្ឌច្បាប់ និងយន្តការប្រឆាំងអំពើពុករលួយ

ប្រទេសចិន មានច្បាប់ប្រឆាំងអំពើពុករលួយសំខាន់ៗចំនួន២ ដូចជាច្បាប់ព្រហ្មទណ្ឌ និងច្បាប់ប្រឆាំងភាពមិនត្រឹមត្រូវក្នុងការប្រកួតប្រជែង (Anti-unfair Competition Law)។[7]

- **ច្បាប់ព្រហ្មទណ្ឌ** ត្រូវបានអនុម័ត នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ១៩៧៩។[14] ការធ្វើវិសោធនកម្មលើកទី៨ នៃច្បាប់នេះ ត្រូវបានធ្វើឡើង នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១១[15] និងការធ្វើវិសោធនកម្មថ្មីៗនេះ គឺធ្វើឡើង នៅក្នុងឆ្នាំ២០១៥។[16] ច្បាប់ព្រហ្មទណ្ឌ ហាមឃាត់អំពើពុករលួយគ្រប់ រូបភាព ជាពិសេសការសូកប៉ាន់ដែលជាប់ពាក់ព័ន្ធនឹងមន្ត្រីរដ្ឋាភិបាល មន្ត្រីមុខងារសាធារណៈ (public functionaries) ក៏ដូចជាមន្ត្រីជាជនជាតិបរទេស ដែលកំពុងបម្រើការងារនៅក្នុងប្រទេស ចិន។[17] ឧទាហរណ៍ ជនណា ដែលផ្តល់អចលនទ្រព្យ ទៅកាន់មន្ត្រីរដ្ឋាភិបាល ដើម្បីទទួលបានផលប្រយោជន៍ ដោយខុសច្បាប់ ត្រូវបានចាត់ទុកថាបានប្រព្រឹត្តការសូកប៉ាន់ ដូចមានចែងក្នុងមាត្រា៣៨៩នៃច្បាប់ព្រហ្មទណ្ឌ។[14] ការផ្តន្ទាទោស គឺការជាប់ពន្ធនាគាររហូតអស់មួយជីវិត និងការរឹបអូសទ្រព្យសម្បត្តិ។[18] ចំពោះជនដែលសូកប៉ាន់មន្ត្រីមិនមែនរដ្ឋាភិបាល ការផ្តន្ទាទោស គឺការជាប់ពន្ធនាគាររហូតដល់រយៈពេល១០ឆ្នាំ និងការផាកពិន័យក្នុងចំនួនមួយយ៉ាងសមរម្យ។[18]
- **ច្បាប់ប្រឆាំងភាពមិនត្រឹមត្រូវក្នុងការប្រកួតប្រជែង (Anti-unfair Competition Law)** ត្រូវបានអនុម័ត នៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៩៣ និងបានចូលជាធរមាន នៅថ្ងៃទី១ ខែធ្នូ ឆ្នាំ១៩៩៣។[19] ច្បាប់នេះ ធានាការប្រកួតប្រជែងដោយស្មើភាពរបស់សហគ្រាសអាជីវកម្ម និងការផ្តល់សេវា និងទំនិញកាន់តែល្អប្រសើរដល់អតិថិជន។[20] ច្បាប់ប្រឆាំងភាពមិនត្រឹមត្រូវក្នុងការប្រកួតប្រជែង (Anti-unfair Competition Law) ហាមឃាត់ការសូកប៉ាន់ (ជាប្រាក់ ឬជា

ទំនិញ) ដែលអាចកើតមាននៅក្នុងពាណិជ្ជកម្ម។ យោងតាមមាត្រា៨ នៃច្បាប់ប្រឆាំងភាពមិនត្រឹមត្រូវក្នុងការប្រកួតប្រជែង (Anti-unfair Competition Law) សហគ្រាសអាជីវកម្ម មិនត្រូវធ្វើការសូកប៉ាន់ នៅក្នុងប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃឡើយ។[20] ជនដែលសូកប៉ាន់ នឹងត្រូវពិន័យជាប្រាក់ចាប់ពីប្រមាណ១០,០០០យ័ន (ប្រហែល១,៥០០ដុល្លារអាមេរិក) ដល់ប្រមាណ២០០,០០០យ័ន (ប្រហែល៣០,០០០ដុល្លារអាមេរិក) ហើយទ្រព្យសម្បត្តិខុសច្បាប់ នឹងត្រូវរឹបអូស ដោយយោងតាមមាត្រា២២ នៃច្បាប់នេះ។[20]

ក្រៅពីច្បាប់ទាំងពីរនេះ តុលាការកំពូល (Supreme People's Court) និងស្ថាប័នអយ្យការកំពូល (Supreme People's Procuratorate) បានចេញឯកសារច្បាប់មួយចំនួន រួមមាន (១) ***ទស្សនៈស្ដីពីបញ្ហាមួយចំនួននៃការអនុវត្តច្បាប់ ស្ដីពីការដោះស្រាយរឿងក្ដីព្រហ្មទណ្ឌ ពាក់ព័ន្ធនឹងការសូកប៉ាន់ក្នុងពាណិជ្ជកម្ម ឆ្នាំ២០០៨ (Opinions on Several Issues of Application of Law concerning the Handling of Criminal Cases of Commercial Bribery)*** និង (២) ***ការបកស្រាយទៅលើបញ្ហាមួយចំនួន ស្ដីពីការអនុវត្តច្បាប់ ស្ដីពីការដោះស្រាយរឿងក្ដីព្រហ្មទណ្ឌ ពាក់ព័ន្ធនឹងការសូកប៉ាន់ ឆ្នាំ២០១២ (the Interpretation of Several Issues concerning the Application of Law for Handling Criminal Cases of Bribery)***។[18] ឯកសារច្បាប់ទាំងពីរនេះ មានតម្លៃស្មើនឹងច្បាប់របស់ប្រទេសចិន ហើយឯកសារទាំងនេះ ចង្អុលបង្ហាញពីវិធីសាស្ត្រ ដែលអ្នកត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិ (regulators) បកស្រាយច្បាប់ប្រឆាំងអំពើពុករលួយ។[21] ម្យ៉ាងវិញទៀត ប្រទេសចិន គឺជារដ្ឋភាគីនៃ***អនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ ឆ្នាំ២០០៣ (the United Nations Convention against Corruption)*** និងជាសមាជិកនៃ***អង្គការអន្តរជាតិពាក់ព័ន្ធនឹងសកម្មភាពហិរញ្ញវត្ថុ***[e] ***ឆ្នាំ២០០៧ (the Financial Action Task Force)***។[21]

ដូចបានរៀបរាប់ខាងលើ នាពេលបច្ចុប្បន្ន យុទ្ធនាការប្រឆាំងអំពើពុករលួយរបស់លោកប្រធានាធិបតី Xi Jinping ទទួលរងនូវការរិះគន់យ៉ាងខ្លាំង។ ថ្វីត្បិតតែមានការរិះគន់យ៉ាងនេះក្ដី ប៉ុន្តែច្បាប់របស់ប្រទេសចិន ដូចដែលបានបង្ហាញនៅខាងលើ ត្រូវបានពង្រឹង ដោយសាររដ្ឋាភិបាល កំពុងធ្វើការស៊ើបអង្កេត មិនត្រឹមតែទៅលើមន្ត្រីប៉ុណ្ណោះទេ ថែមទាំងធ្វើការស៊ើបអង្កេតនៅក្នុងវិស័យឯកជនផងដែរ។[16] តាមរយៈយុទ្ធនាការដ៏ធំមួយនេះ សភារបស់ប្រទេសចិន (ដែលហៅថា «សភាជាតិប្រជាមានិត

[e] អង្គការអន្តរជាតិពាក់ព័ន្ធនឹងសកម្មភាពហិរញ្ញវត្ថុ (the Financial Action Task Force) គឺជាអង្គការអន្តររដ្ឋាភិបាល ដែលមានគោលបំណងបង្កើត និងលើកកម្ពស់គោលនយោបាយ ដើម្បីប្រយុទ្ធប្រឆាំងនឹង*ការលាងលុយកខ្វក់ (money laundering) និងហិរញ្ញប្បទានភេរវកម្ម (terrorist financing)*។

ចិន» *National People's Congress of China*) បានធ្វើវិសោធនកម្មច្បាប់ព្រហ្មទណ្ឌ កាលពី២ឆ្នាំមុន។ ក្រៅពីនេះ បទប្បញ្ញត្តិប្រឆាំងអំពើពុករលួយមួយចំនួនទៀត ត្រូវបានចេញដោយស្ថាប័នពាក់ព័ន្ធ ខុសៗគ្នា ដូចខាងក្រោម៖[16]

- ***បទប្បញ្ញត្តិ ស្តីពីការបង្កើតកំណត់ត្រានៃការសូកប៉ាន់ក្នុងពាណិជ្ជកម្ម ពាក់ព័ន្ធនឹងការទិញលក់ឧបករណ៍វេជ្ជសាស្ត្រ និងឱសថ (the Regulations on the Establishment of Commercial Bribery Records in Medical Device and Pharmaceutical Sales and Purchase Areas)*** ចេញដោយគណៈកម្មការសុខភាពជាតិ និងផែនការគ្រួសារ (National Healthcare and Family Planning Commission) ឆ្នាំ២០១៣[16]
- ***បទប្បញ្ញត្តិនៃស្ថាប័នអយ្យការកំពូល ស្តីពីការស៊ើបសួរពាក់ព័ន្ធនឹងសំណុំរឿងសូកប៉ាន់ (the Provisions of the Supreme People's Procuratorate on Bribery Case File Inquiry)*** ចេញដោយស្ថាប័នអយ្យការកំពូល (Supreme People's Procuratorate) ឆ្នាំ២០១៣[16] និង
- ***បទប្បញ្ញត្តិបណ្តោះអាសន្ន ស្តីពីការបង្ហាញព័ត៌មាន ស្តីពីការដាក់ទោសទណ្ឌរដ្ឋបាល ពាក់ព័ន្ធនឹងរដ្ឋបាលនៅក្នុងវិស័យឧស្សាហកម្ម និងពាណិជ្ជកម្ម (the Interim Provisions on the Disclosure of the Information on Administration Punishments concerning Industrial and Commercial Administration)*** ចេញដោយរដ្ឋបាលក្នុងវិស័យឧស្សាហកម្ម និងពាណិជ្ជកម្ម (the State Administration for Industry and Commerce) ឆ្នាំ ២០១៤។[16]

## ២.៤. ទំនាក់ទំនងរវាងប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ និងដំណើរការប្រឆាំងអំពើពុករលួយ

ហេតុផលមួយចំនួន បានបង្ហាញឲ្យឃើញថា កិច្ចខិតខំប្រឹងប្រែងប្រឆាំងអំពើពុករលួយ នៅក្នុងដំណើរការវិមជ្ឈការ និងវិសហមជ្ឈការនៅប្រទេសចិន នៅតែមិនទាន់មានប្រសិទ្ធភាពនៅឡើយ។ ដោយសារអាជ្ញាធរមូលដ្ឋាន អាចអនុវត្តច្បាប់ និងគោលនយោបាយផ្សេងពីគ្នាបាន ដំណើរការនៃការប្រឆាំងអំពើពុករលួយនៅថ្នាក់មូលដ្ឋាន ជាពិសេសនៅថ្នាក់ខេត្ត ក៏មានលក្ខណៈផ្សេងពីគ្នាដែរ។[9] លើសពីនេះទៀត អំពើពុករលួយ មាននិយមន័យខុសៗគ្នា នៅទូទាំងប្រទេសចិន។ ដូច្នេះ សកម្មភាពជាក់លាក់មួយចំនួន ដែលជាទូទៅត្រូវបានចាត់ទុកជាអំពើពុករលួយ ប្រហែលជាមិនមែនជាអំពើពុករលួយនៅក្នុងបរិបទប្រទេសចិនឡើយ។[9] ម្យ៉ាងវិញទៀត អាជ្ញាធរថ្នាក់ខេត្តមួយចំនួន ចាត់ទុកការកេងបន្លំ

ថវិកា (embezzlement) ជាការប្រព្រឹត្តខុសតិចតួច ទោះបីជាទង្វើនេះ ប្រឆាំងនឹងច្បាប់ព្រហ្មទណ្ឌរបស់ប្រទេសចិនក៏ដោយ។ ក្នុងន័យនេះ មន្ត្រីរដ្ឋាភិបាលជាច្រើននាក់ ត្រូវបានលើកលែងពីការដាក់ទណ្ឌកម្ម ឬផ្ទុយទៅវិញ មន្ត្រីទាំងនោះ អាចនឹងត្រូវគណបក្ស ផ្តន្ទាទោសជំនួសវិញ។[9]

ជាងនេះទៅទៀត យោងតាមច្បាប់របស់ប្រទេសចិន ការបោះឆ្នោតជ្រើសរើសមេភូមិ (នៅថ្នាក់ក្រុង) ត្រូវតែប្រព្រឹត្តធ្វើឡើង ប៉ុន្តែការសម្រេចរៀបចំការបោះឆ្នោត គឺស្ថិតនៅក្រោមសេចក្តីសម្រេចចិត្តរបស់ រដ្ឋាភិបាលថ្នាក់ក្រុង។ ផ្ទុយទៅវិញ មេភូមិ ត្រូវបានតែងតាំង ដោយគណបក្សនយោបាយ។[9] នេះគឺដើម្បីធានាថា មេភូមិ មិនធ្វើឲ្យរាំងស្ទះដល់ការអនុវត្តបទបញ្ជា (mandates)។ ទោះជាយ៉ាងណា កត្តានេះ ធ្វើឲ្យមានការកើនឡើងចំនួនមន្ត្រីរដ្ឋាភិបាលពុករលួយនៅថ្នាក់ក្រុង។[9]

នៅក្នុងដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ អាជ្ញាធរមូលដ្ឋានគ្រប់កម្រិត ចូលរួមក្នុងដំណើរការប្រឆាំងអំពើពុករលួយ ដោយផ្អែកទៅលើអាទិភាពនៃបទបញ្ជា (rule of mandates) (ការគ្រប់គ្រងដោយផ្អែកលើអាទិភាពជាជាងផ្អែកលើច្បាប់)។[9] ការស៊ើបអង្កេតអំពើពុករលួយ ជាធម្មតាមិនចាប់ផ្តើម ធ្វើនៅពេលមានការប្រព្រឹត្តបទល្មើសនោះទេ ដោយការស៊ើបអង្កេតនោះ ធ្វើឡើងតែនៅពេលដែលមានរបាយការណ៍ពីគណបក្ស ពាក់ព័ន្ធនឹងការប្រព្រឹត្តខុសរបស់សមាជិកប៉ុណ្ណោះ។ លើសពីនេះទៅទៀត ដោយសារព័ត៌មានចាំបាច់សម្រាប់ការស៊ើបអង្កេត នៅមានកម្រិត អាជ្ញាធរមូលដ្ឋានគ្រប់កម្រិតដែលដឹងពីស្ថានភាពនេះ អាចបិទបាំងបទល្មើសរបស់ខ្លួន បានយ៉ាងងាយស្រួល។[9]

## ៣. ប្រទេសអូស្ត្រាលី

### *៣.១. ស្ថានភាពបច្ចុប្បន្ននៃការប្រឆាំងអំពើពុករលួយ និងប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ នៅប្រទេសអូស្ត្រាលី*

### *៣.១.១. ការប្រឆាំងអំពើពុករលួយ*

- *អំពើពុករលួយ*

ស្រដៀងគ្នាទៅនឹងប្រទេសចិនដែរ អំពើពុករលួយនៅប្រទេសអូស្ត្រាលី ភាគច្រើនកើតមាននៅក្នុងប្រព័ន្ធនយោបាយ។ កិច្ចខិតខំប្រឹងប្រែងក្នុងការដោះស្រាយបញ្ហានេះ កើតមាននៅក្នុងទសវត្សរ៍ឆ្នាំ ១៩៨០ និងទសវត្សរ៍ឆ្នាំ១៩៩០។[22] ទោះបីជាមានការខិតខំប្រឹងប្រែងយ៉ាងនេះក្តី ក៏ប្រទេសអូស្ត្រាលី ហាក់ដូចជានៅតែមានអំពើពុករលួយ ក្នុងចំណោមមន្ត្រី ដែលកាន់មុខតំណែងខ្ពស់។[22]

ការស្ទង់មតិជាតិ ដែលបានធ្វើឡើងនៅក្នុងឆ្នាំ២០១២ បានបង្ហាញឲ្យឃើញថា អំពើពុករលួយក្នុងរូបភាពជាការសូកប៉ាន់ គឺមិនមានខ្ពស់នោះទេ។ ប្រជាពលរដ្ឋស្ទើរតែគ្រប់រូប មិនធ្លាប់ជួបប្រទះនឹងការសូកប៉ាន់ នៅពេលពួកគេ ទទួលសេវាសាធារណៈឡើយ។[22] ទោះជាយ៉ាងណា នៅក្នុងវិស័យការងារ ជាពិសេសពលករវ័យក្មេង ងាយជួបប្រទះនឹងការសូកប៉ាន់។[22] គួរឲ្យកត់សម្គាល់ផងដែរថា ស្ថាប័ននៅក្នុងប្រទេសអូស្ត្រាលី ដូចជាកងកម្លាំងការពារជាតិអូស្ត្រាលី (the Australian Defense Force) ស្ថាប័នផ្តល់សេវាសាធារណៈ និងកងកម្លាំងនគរបាល មានអំពើពុករលួយទាបបំផុត ខណៈពេលដែលប្រព័ន្ធផ្សព្វផ្សាយ សហជីពពាណិជ្ជកម្ម និងគណបក្សនយោបាយ ងាយមានអំពើ-ពុករលួយ។[22]

យោងតាមអង្គការតម្លាភាពអន្តរជាតិ (Transparency International Organization) ប្រទេសអូស្ត្រាលី ទទួលបាន៧៩ពិន្ទុ (នៃ១០០ពិន្ទុ) នៅក្នុងឆ្នាំ២០១៦ ដូចនៅក្នុងឆ្នាំ២០១៥ដែរ (សូមមើលរូបភាពទី១ខាងលើ)។[6] ជាការពិតណាស់ ពិន្ទុនៅចន្លោះឆ្នាំ២០១២ និងឆ្នាំ២០១៦ មានការធ្លាក់ចុះបន្តិច ប៉ុន្តែពិន្ទុនេះ នៅតែបង្ហាញថា ប្រទេសអូស្ត្រាលី គឺជាប្រទេសមួយ ដែលមានអំពើពុករលួយទាបបំផុត។[6]

❖ *យន្តការប្រឆាំងអំពើពុករលួយ*

ប្រទេសអូស្ត្រាលី បានបង្កើតភ្នាក់ងារប្រឆាំងអំពើពុករលួយមួយចំនួន នៅក្នុងរដ្ឋផ្សេងៗគ្នា ដែលមានដូចខាងក្រោម៖[23]

- គណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយ (Independent Commission against Corruption) នៅរដ្ឋ New South Wales ក្នុងឆ្នាំ១៩៨៨
- គណៈកម្មការឧក្រិដ្ឋកម្ម និងអំពើពុករលួយ (Crime and Corruption Commission) នៅរដ្ឋ Queensland ក្នុងឆ្នាំ១៩៩១
- គណៈកម្មការអំពើពុករលួយ និងឧក្រិដ្ឋកម្ម (Corruption and Crime Commission) នៅរដ្ឋWestern Australia ក្នុងឆ្នាំ១៩៩២
- គណៈកម្មការសុចរិតភាព (Integrity Commission) នៅរដ្ឋ Tasmania ក្នុងឆ្នាំ២០១០
- គណៈកម្មការឯករាជ្យប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយក្នុងទ្រង់ទ្រាយធំ (Independent Broad-based Anti-Corruption Commission) នៅរដ្ឋ Victoria ក្នុងឆ្នាំ២០១២ និង
- គណៈកម្មការឯករាជ្យប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ (Independent Commissioner against Corruption ) នៅរដ្ឋ South Australia ក្នុងឆ្នាំ២០១២។[23]

ក្រៅពីភ្នាក់ងារទាំងនេះ រដ្ឋាភិបាលប្រទេសអូស្ត្រាលី ក៏បានបង្កើតគណៈកម្មការពីរផ្សេងទៀត ដើម្បីពង្រឹងសមត្ថភាពប្រយុទ្ធប្រឆាំងអំពើពុករលួយ ដែលមានដូចខាងក្រោម៖

- គណៈកម្មការពង្រឹងការអនុវត្តច្បាប់អូស្ត្រាលី (Australian Commission for Law Enforcement Integrity) ធ្វើការស៊ើបអង្កេតទៅលើការអនុវត្តច្បាប់ ពាក់ព័ន្ធនឹងអំពើពុក-រលួយ ដោយផ្តល់អាទិភាពចំពោះការប្រព្រឹត្តអំពើពុករលួយធ្ងន់ធ្ងរ និងជាប្រព័ន្ធ (ឆ្នាំ ២០០៤) និង
- មជ្ឈមណ្ឌលសហព័ន្ធប៉ូលីសបង្ក្រាបការក្លែងបន្លំ និងការប្រឆាំងអំពើពុករលួយអូស្ត្រាលី (Australian Federal Police Fraud and Anti-corruption) ស៊ើបអង្កេតការអនុវត្តច្បាប់ពាក់ព័ន្ធនឹងការក្លែងបន្លំ (fraud) ការសូកប៉ាន់ជនជាតិបរទេស (foreign bribery) និងអំពើពុករលួយ ដែលមន្ត្រីរដ្ឋាភិបាលអូស្ត្រាលី បានប្រព្រឹត្ត (ឆ្នាំ២០១៣)។[23]

លើសពីនេះទៅទៀត ភ្នាក់ងារមួយចំនួនទៀត ក៏បានចូលរួមចំណែកប្រឆាំងអំពើពុករលួយ ក្នុងវិស័យឯកជនផងដែរ ដូចជា៖[22]

- មជ្ឈមណ្ឌលរបាយការណ៍ប្រតិបត្តិការពាណិជ្ជកម្ម និងវិភាគអូស្ត្រាលី (Australian Transaction Reports and Analysis Centre) ធ្វើការស៊ើបអង្កេតឧក្រិដ្ឋកម្មទូទៅ រួមទាំងបទល្មើសពាក់ព័ន្ធនឹងអំពើពុករលួយផងដែរ នៅក្នុងរូបភាពជាការលាងលុយកខ្វក់ (money laundering) និងការផ្តល់ថវិកាគាំទ្រសកម្មភាពភេរវកម្ម។[22]
- គណៈកម្មការប្រកួតប្រជែង និងការប្រើប្រាស់អូស្ត្រាលី (Australian Competition and Consumer Commission) ផ្តល់ការបណ្តុះបណ្តាលទៅលើការធ្វើពាក្យបណ្តឹង និងការជៀសវាងនូវការប្រព្រឹត្តអំពើពុករលួយ ដល់សហគ្រាសអាជីវកម្ម និងសាធារណជនទូទៅ។[22]
- អាជ្ញាធរបទប្បញ្ញត្តិអូស្ត្រាលី (Australian Prudential Regulation Authority) ត្រួតពិនិត្យប្រតិបត្តិការរបស់ធនាគារ និងស្ថាប័នពាក់ព័ន្ធ។[22]
- គណៈកម្មការមូលបត្រ និងការវិនិយោគអូស្ត្រាលី (Australian Securities and Investments Commission) ស៊ើបអង្កេតសកម្មភាពខុសច្បាប់ក្នុងក្រុមហ៊ុនសាជីវកម្ម។[22]

### ៣.១.២. ប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ

ប្រទេសអូស្ត្រាលី គឺជាសហព័ន្ធរដ្ឋ ដែលមានរដ្ឋចំនួន៦ និងរដ្ឋបាលដែនដី២ផ្សេងទៀត (two-self-governing territories) ដោយនៅក្នុងនោះ រដ្ឋនីមួយៗ មានរដ្ឋធម្មនុញ្ញ សភា និងច្បាប់រៀងៗខ្លួន

(សូមមើលរូបភាពទី៣ខាងក្រោម)។[24] រដ្ឋាភិបាលសហព័ន្ធ និងថ្នាក់រដ្ឋ មានស្ថាប័នអំណាចចំនួន ៣ ដូចជាអំណាចនីតិប្រតិបត្តិ អំណាចនីតិបញ្ញត្តិ និងអំណាចតុលាការ។ ពាក់ព័ន្ធទៅនឹងការអនុម័តច្បាប់ រដ្ឋាភិបាលសហព័ន្ធ មានអំណាចបង្កើតច្បាប់ស្តីពីការប្រមូលពន្ធ និងកិច្ចការបរទេស ក៏ដូចជាច្បាប់ស្តីពីកិច្ចការពារជាតិផងដែរ។[24] ទន្ទឹមនឹងនេះ រដ្ឋនីមួយៗ អាចអនុម័តច្បាប់ផ្សេងពីគ្នា ស្តីពីការអប់រំ លំហែរទាំសុខភាព និងការដឹកជញ្ជូនសាធារណៈ ដើម្បីអនុវត្តនៅក្នុងដែនដីរបស់ខ្លួន។ ទោះបីជារដ្ឋាភិបាលថ្នាក់រដ្ឋ មានអំណាចនីតិបញ្ញត្តិក៏ដោយ ក៏រដ្ឋាភិបាលថ្នាក់សហព័ន្ធ នៅតែអាចបង្កើតច្បាប់ ដែលអាចមានឥទ្ធិពលទៅលើរដ្ឋទាំងនោះដែរ ហេតុដូច្នេះ ការខ្វែងគំនិតគ្នាពាក់ព័ន្ធនឹងការអនុម័តច្បាប់ គឺនៅតែកើតមាន។[24]

ក្រៅពីរដ្ឋាភិបាលទាំងពីរកម្រិតនេះ (ថ្នាក់សហព័ន្ធ និងថ្នាក់រដ្ឋ) រដ្ឋបាលមូលដ្ឋាន ក៏ត្រូវបានបង្កើតឲ្យមាននៅក្នុងរដ្ឋនីមួយៗ និងរដ្ឋបាលដែនដីតំបន់ Northern Territory of Australiaផងដែរ ដូចដែលបានបង្ហាញនៅក្នុងរូបភាពទី៣។ រដ្ឋបាលនេះ អាចហៅថា រដ្ឋបាលថ្នាក់មូលដ្ឋាន ឬក្រុមប្រឹក្សាមូលដ្ឋាន[f]។ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលថ្នាក់រដ្ឋ និងរដ្ឋបាលដែនដីតំបន់ Northern Territory of Australia រដ្ឋបាលថ្នាក់មូលដ្ឋាន ទទួលខុសត្រូវចំពោះការប្រមូលសំរាម និងការរៀបចំផែនការអភិវឌ្ឍន៍ទីក្រុង។[24]

[f] រដ្ឋបាលថ្នាក់មូលដ្ឋាន អាចត្រូវបានគេហៅខុសៗថា cities, shires, towns ឬ municipalitiesជាដើម (ដែលមានន័យជារួមថា ទីក្រុង)។

**រូបភាពទី៣៖ ប្រព័ន្ធរដ្ឋាភិបាលរបស់ប្រទេសអូស្ត្រាលី**




នៅចន្លោះឆ្នាំ២០១៤ និងឆ្នាំ២០១៥ រដ្ឋបាលថ្នាក់មូលដ្ឋាននៅក្នុងប្រទេសអូស្ត្រាលី មានចំនួនប្រមាណ៥៧០រដ្ឋបាលមូលដ្ឋាន។[25] រដ្ឋាភិបាលថ្នាក់សហព័ន្ធ រដ្ឋាភិបាលថ្នាក់រដ្ឋ និងរដ្ឋបាលថ្នាក់មូលដ្ឋាន ធ្វើការបែងចែកចំណូលទទួលបានពីពន្ធ ដូចបានបង្ហាញក្នុងតារាងទី២ខាងក្រោម។

**តារាងទី២៖ ការបែងចែកចំណូលពន្ធ (tax-sharing revenue) របស់រដ្ឋាភិបាលប្រទេសអូស្ត្រាលី នៅចន្លោះឆ្នាំ២០១៤ និងឆ្នាំ២០១៥[25]**

| ប្រភពចំណូល | ថ្នាក់សហព័ន្ធ % | ថ្នាក់រដ្ឋ % | ថ្នាក់មូលដ្ឋាន % | សរុប % |
|---|---|---|---|---|
| ពន្ធលើប្រាក់ចំណូល (Taxes on income) | ៥៨.០ | - | - | ៥៨.០ |
| ពន្ធលើប្រាក់បៀវត្សរ៍និយោជក (Employers payroll taxes) | ០.២ | ៥.០ | - | ៥.០ |
| ពន្ធលើអចលនទ្រព្យ (Taxes on property) | - | ៦.៦ | ៣.៥ | ១០.១ |
| ពន្ធលើការផ្តល់ទំនិញ និងសេវា (Taxes on provision of goods and services) | ២០.៩ | ២.៥ | - | ២៣.៤ |

| | | | | |
|---|---|---|---|---|
| ពន្ធលើការប្រើប្រាស់ទំនិញ និងប្រតិបត្តិការ ( Taxes on use of goods and performance activities ) | ១.១ | ២.៤ | - | ៣.៥ |
| **សរុប** | **៨០.១** | **១៦.៥** | **៣.៥** | **១០០** |

**កំណត់សម្គាល់៖ 0.២<0.៥ មិនបានរាប់បញ្ចូលទេ**

**ប្រភព៖ រដ្ឋាភិបាលប្រទេសអូស្ត្រាលី នាយកដ្ឋានអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងតំបន់**

## ៣.២. បញ្ហាប្រឈមចំពោះដំណើរការប្រឆាំងអំពើពុករលួយ

ទោះបីជាប្រទេសអូស្ត្រាលី មានសន្ទស្សន៍នៃអំពើពុករលួយទាប ដំណើរការប្រឆាំងអំពើពុករលួយ នៅតែប្រឈមនឹងបញ្ហាមួយចំនួនដូចខាងក្រោម៖

- **អវត្តមានភ្នាក់ងារប្រឆាំងអំពើពុករលួយកម្រិតសហព័ន្ធ (Commonwealth anti-corruption agency)៖** ប្រទេសអូស្ត្រាលី មានភ្នាក់ងារប្រឆាំងអំពើពុករលួយជាច្រើន ដែលស្ថិតនៅក្នុងរដ្ឋនីមួយៗ និងមានភ្នាក់ងារ២ផ្សេងទៀត នៅកម្រិតរដ្ឋាភិបាលថ្នាក់សហព័ន្ធ។ ទោះជាយ៉ាងណា សិទ្ធិអំណាចក្នុងការប្រឆាំងអំពើពុករលួយ របស់ភ្នាក់ងារនៅថ្នាក់សហព័ន្ធទាំងពីរនេះ ជាពិសេសគណៈកម្មការពង្រឹងការអនុវត្តច្បាប់អូស្ត្រាលី (Australian Commission for Law Enforcement Integrity) នៅមានកម្រិតនៅឡើយ។ ឧទាហរណ៍ យុត្តាធិការរបស់ភ្នាក់ងារទាំងពីរ មានតែនៅលើប៉ូលីសសហព័ន្ធអូស្ត្រាលី (Australian Federal Police) និងគណៈកម្មការឧក្រិដ្ឋកម្មអូស្ត្រាលី (Australian Crime Commission) ប៉ុណ្ណោះ។ ភ្នាក់ងារប្រឆាំងអំពើពុករលួយនៅថ្នាក់សហព័ន្ធ មិនមានអំណាចស៊ើបអង្កេតស្ថាប័ន សាធារណៈមួយចំនួនធំនៅក្នុងប្រទេសអូស្ត្រាលី។ ដូច្នេះ អ្វីដែលចាំបាច់នោះ គឺការបង្កើតឲ្យមានភ្នាក់ងារប្រឆាំងអំពើពុករលួយកម្រិតសហព័ន្ធ (Commonwealth anti-corruption agency) ដែលមានអំណាចគ្របដណ្តប់ទៅលើស្ថាប័នទាំងអស់ នៅប្រទេសអូស្ត្រាលី។[26]
- **ការពឹងផ្អែកទៅលើអ្នកកាសែត៖** អវត្តមានភ្នាក់ងារប្រឆាំងអំពើពុករលួយកម្រិតសហព័ន្ធ (Commonwealth anti-corruption agency) បង្ហាញឲ្យឃើញថា ប្រទេសអូស្ត្រាលី ពេលខ្លះពឹងផ្អែកទៅលើអ្នកកាសែត ដើម្បីរាយការណ៍ពីការប្រព្រឹត្តខុសរបស់មន្ត្រី ឬបុគ្គលណាម្នាក់។ យ៉ាងណាមិញ សកម្មភាពរបស់អ្នកកាសែត ត្រូវបានកំណត់ដោយច្បាប់ស្តីពីបទបរិហាកេរ្តិ៍របស់ប្រទេសអូស្ត្រាលី (Australian Defamation Laws)។[26] ម្យ៉ាងទៀត ការស្ទង់មតិ

ជាតិ នៅក្នុងឆ្នាំ២០១២ បានបង្ហាញឲ្យឃើញថា ប្រជាពលរដ្ឋ មិនសូវជឿជាក់ទៅលើប្រព័ន្ធផ្សព្វផ្សាយឡើយ ហើយពួកគេ យល់ឃើញថា ប្រព័ន្ធផ្សព្វផ្សាយ ជាភ្នាក់ងារដែលងាយនឹងមានអំពើពុករលួយ។ ទោះបីជាការយល់ឃើញនេះ ពិត ឬមិនពិតក៏ដោយ ភាពជឿជាក់របស់សាធារណជន ទៅលើប្រព័ន្ធផ្សព្វផ្សាយ គឺត្រូវបានបំផ្លាញ ដោយភ្នាក់ងារនេះ ប្រហែលមិនអាចធ្វើជាភ្នាក់ងារឃ្លាំមើលអំពើពុករលួយបានឡើយ។[22]

- **កង្វះខាតធនធាន៖** ប្រទេសអូស្ត្រាលី យកចិត្តទុកដាក់យ៉ាងខ្លាំង ចំពោះការបង្កើតច្បាប់ប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ។ ទោះជាយ៉ាងណាក៏ដោយ ក្របខ័ណ្ឌច្បាប់ទាំងនោះ គឺមិនទាន់មានប្រសិទ្ធភាព ដូចដែលបានរំពឹងទុកឡើយ ពីព្រោះរដ្ឋាភិបាល មិនបានផ្តល់ធនធានគ្រប់គ្រាន់ រួមមានធនធានហិរញ្ញវត្ថុ និងធនធានបច្ចេកទេស ដើម្បីពង្រឹងច្បាប់ទាំងនោះ។[22]
- **កង្វះការយល់ដឹងរបស់ប្រជាពលរដ្ឋ៖** ប្រជាពលរដ្ឋអូស្ត្រាលី មិនទាន់យល់ច្បាស់ពីមធ្យោបាយដើម្បីចូលរួមចំណែកក្នុងការប្រឆាំងអំពើពុករលួយឡើយ។ ប្រជាពលរដ្ឋភាគច្រើន នៅមិនទាន់ដឹងថាមានភ្នាក់ងារប្រឆាំងអំពើពុករលួយឡើយ។ ផ្ទុយទៅវិញ ពួកគេ ជាធម្មតារាយការណ៍ពីអំពើពុករលួយទៅកាន់ប៉ូលីស ឬការិយាល័យប្រជាពលរដ្ឋ (ombudsman) ដោយមិនបានរាយការណ៍ទៅភ្នាក់ងារប្រឆាំងអំពើពុករលួយឡើយ។[22]

## ៣.៣. ក្របខ័ណ្ឌច្បាប់ និងយន្តការក្នុងការប្រឆាំងអំពើពុករលួយ

***ក្រមព្រហ្មទណ្ឌឆ្នាំ១៩៩៥ (Criminal Code Act 1995)*** គឺជាច្បាប់ប្រឆាំងអំពើពុករលួយដ៏សំខាន់នៅក្នុងប្រទេសអូស្ត្រាលី។ ក្រមនេះ ចែងពីអំពើពុករលួយក្នុងរូបភាពជាការសូកប៉ាន់ ដែលមន្ត្រីរដ្ឋាភិបាលបរទេស[g] បានប្រព្រឹត្ត ដូចមានចែងនៅក្នុងផ្នែក៧០នៃក្រមនេះ។[27] ផ្នែក៧០ កំណត់ជនដែលសូកប៉ាន់ (briber) ជា*ជនទាំងឡាយណា ដែលបានផ្តល់អត្ថប្រយោជន៍ណាមួយ ទៅកាន់ជនម្នាក់ផ្សេងទៀត ដើម្បីទទួលបាន ឬរក្សាផលប្រយោជន៍*។ ការផ្តន្ទាទោស គឺការជាប់ពន្ធនាគាររយៈពេល១០ឆ្នាំ។ ទោះជាយ៉ាងណា យោងតាម***ច្បាប់ឧក្រិដ្ឋកម្មឆ្នាំ១៩១៤ (Crime Act 1914)*** ផ្នែក៤B តុលាការ អាចកំណត់ការផាកពិន័យ (១០,000 Penalty Units[h] / ប្រមាណ១.១លានដុល្លារអាមេរិក) និង/ឬ

[g] ក្រមនេះ ត្រូវបានធ្វើវិសោធនកម្មលើផ្នែកការសូកប៉ាន់របស់មន្ត្រីរដ្ឋាភិបាលបរទេស នៅក្នុងឆ្នាំ១៩៩៩ ***(វិសោធនកម្មក្រមព្រហ្មទណ្ឌ៖ ការសូកប៉ាន់របស់មន្ត្រីរដ្ឋាភិបាលបរទេស ឆ្នាំ១៩៩៩)***។

[h] Penalty Units ត្រូវបានកំណត់ជារៀងរាល់ឆ្នាំដោយក្រសួងរតនាគារ និងហិរញ្ញវត្ថុ និងត្រូវបានធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី១ ខែកក្កដា ជារៀងរាល់ឆ្នាំ។

ការជាប់ពន្ធនាគារ។[22, 27] ក្រមព្រហ្មទណ្ឌឆ្នាំ១៩៩៥ ក៏អាចប្រើប្រាស់ចំពោះក្រុមហ៊ុនសាជីវកម្ម ផងដែរ ដែលការផ្តន្ទាទោស គឺធ្ងន់ធ្ងរជាងនេះ។[22]

ក្រៅពីក្រមនេះ ប្រទេសអូស្ត្រាលី ក៏បានបង្កើត និងអនុវត្តច្បាប់មួយចំនួនទៀត ដូចខាងក្រោម៖

- *ច្បាប់ឧក្រិដ្ឋកម្មឆ្នាំ១៩១៤ (Crime Act 1914)៖* នៅក្នុងផ្នែក១៥GEនៃច្បាប់នេះ អំពើពុក-រលួយក្នុងរូបភាពជាការក្លែងបន្លំ (Fraud) និងការលាងលុយកខ្វក់ (Money laundering) ត្រូវបានចាត់ទុកជាបទឧក្រិដ្ឋធ្ងន់ធ្ងរ។ ដូច្នេះ ជនដែលត្រូវបានគេរកឃើញថាបានប្រព្រឹត្តអំពើ-ពុករលួយ នឹងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារប្រហែល៣ឆ្នាំ ឬច្រើនជាងនេះ។[28]
- *ច្បាប់រដ្ឋបាលពន្ធដារឆ្នាំ១៩៥៣ (Taxation Administration Act 1953)*
- *ច្បាប់វាយតំលៃពន្ធលើប្រាក់ចំណូលឆ្នាំ១៩៩៧ (Income Tax Assessment Act 1997)* និង
- *ច្បាប់សាជីវកម្មឆ្នាំ២០០១ (Corporations Act 2001)*។[29]

ប្រទេសអូស្ត្រាលី ជាសមាជិករបស់អង្គការអន្តរជាតិ និងជារដ្ឋភាគីនៃអនុសញ្ញាមួយចំនួន ដែលពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ៖

- *អង្គការអន្តរជាតិពាក់ព័ន្ធនឹងសកម្មភាពហិរញ្ញវត្ថុ (Financial Action Task Force)* ឆ្នាំ ១៩៩០
- *អនុសញ្ញាអង្គការកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ ស្តីពីការប្រយុទ្ធប្រឆាំងការសូកប៉ាន់របស់មន្ត្រីសាធារណៈបរទេស នៅក្នុងប្រតិបត្តិការពាណិជ្ជកម្មអន្តរជាតិ (Organization for Economic Co-operation and Development Convention on Combating Bribery of Foreign Public Officials in International Business Transactions)* ឆ្នាំ១៩៩៩
- *អនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីការប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន (United Nations Convention against Transnational Organized Crime)* ឆ្នាំ២០០៤ និង
- *អនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីការប្រឆាំងអំពើពុករលួយ (United Nations Convention against Corruption)* ឆ្នាំ២០០៥។[18, 29]

## ៣.៤. ទំនាក់ទំនងរវាងប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ និងដំណើរការប្រឆាំងអំពើពុករលួយ

ខណៈពេលដែលប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ ត្រូវបានចាត់ទុកជាឧបករណ៍មួយដ៏សំខាន់ ក្នុងការប្រឆាំងអំពើពុករលួយ អាជ្ញាធរមូលដ្ឋាននៅក្នុងប្រទេសអូស្ត្រាលី មានតួនាទីគ្រប់គ្រងសំរាមបង្កើត និងបំពាក់ឧបករណ៍ក្នុងកន្លែងកំសាន្តសាធារណៈ និងអនុវត្តផែនការអភិវឌ្ឍន៍នានា។[24] ការប្រឆាំងអំពើពុករលួយ គឺជាទំនួលខុសត្រូវរបស់ភ្នាក់ងារប្រឆាំងអំពើពុករលួយ ជាពិសេសភ្នាក់ងារដែលបានបង្កើតនៅក្នុងរដ្ឋនីមួយៗ។

ផ្ទុយពីការរំពឹងទុកចំពោះការដោះស្រាយអំពើពុករលួយនៅថ្នាក់រដ្ឋ អំពើពុករលួយ ត្រូវបានឲ្យនិយមន័យខុសៗគ្នា នៅតាមរដ្ឋនីមួយៗ ដែលនេះ អាចធ្វើឲ្យប៉ះពាល់ដល់យុត្តាធិការរបស់ភ្នាក់ងារប្រឆាំងអំពើ-ពុករលួយ។[23] ឧទាហរណ៍ **គណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយ (Independent Commission against Corruption)** នៅរដ្ឋ New South Wales មិនអាចធ្វើការស៊ើបអង្កេតសកម្មភាពខុសច្បាប់ ដែលព្រះរាជអាជ្ញា Margaret Cunneen SC[i] បានប្រព្រឹត្ត ដោយសារសកម្មភាពទាំងនោះ មិនត្រូវបានកំណត់ជាអំពើពុករលួយ ដូចមានចែងនៅក្នុងច្បាប់គណៈកម្មការឯករាជ្យ ប្រឆាំងអំពើពុករលួយឆ្នាំ១៩៨៨ឡើយ។[30] ភ្នាក់ងារប្រឆាំងអំពើពុករលួយនេះ មិនបានរួមបញ្ចូល ការសូកប៉ាន់ ការជំរិតទារប្រាក់ (Black mail) ការក្លែងបន្លំ (Fraud) និងសកម្មភាពពាក់ព័ន្ធដទៃទៀតដូចនិយមន័យរបស់តុលាការកំពូលប្រទេសអូស្ត្រាលីឡើយ។[30]

លើសពីនេះទៀត ភ្នាក់ងារប្រឆាំងអំពើពុករលួយ អាចមានសិទ្ធិអំណាចខុសៗពីគ្នា នៅទូទាំងប្រទេសអូស្ត្រាលី។[23] ឧទាហរណ៍ **គណៈកម្មការឯករាជ្យប្រឆាំងអំពើពុករលួយ (Independent Commission against Corruption)** នៅរដ្ឋ New South Wales អាចរៀបចំវេទិកាសាធារណៈបាន ខណៈពេលដែល **គណៈកម្មការឯករាជ្យប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ (Independent Commissioner against Corruption)** នៅរដ្ឋ South Australia មិនអាចរៀបចំវេទិកាសាធារណៈបានឡើយ។[23] ម្យ៉ាងវិញទៀត មិនមែនភ្នាក់ងារទាំងអស់ សុទ្ធតែអាចកាត់ទោសជនដែលប្រព្រឹត្តអំពើពុករលួយនោះទេ។ ក្នុងករណីភ្នាក់ងារប្រឆាំងអំពើពុករលួយនៅរដ្ឋ New South Wales ក្រោយ

---

[i] លោកស្រី Margaret Cunneen SC គឺជាព្រះរាជអាជ្ញាជាន់ខ្ពស់នៅក្នុងរដ្ឋ New South Wales។ លោកស្រី ត្រូវបានចោទប្រកាន់ពីបទប៉ុនប៉ងផ្លាស់ប្តូរលទ្ធផលស៊ើបសួររបស់ប៉ូលីស ពាក់ព័ន្ធនឹងគ្រោះថ្នាក់ចរាចរណ៍ ដែលមិត្តស្រីកូនប្រុសរបស់លោកស្រី មានការពាក់ព័ន្ធ។ ករណីនេះ ត្រូវបានគេហៅថា «ការបង្កឲ្យមានភាពអយុត្តិធម៌ (pervert the course of justice)»។

ពីការរកឃើញអំពើ-ពុករលួយ ភ្នាក់ងារ មិនបានចាត់វិធានការបន្តបន្ទាប់ទៀតនោះទេ។ ដូច្នេះហើយ ការជជែកពិភាក្សាជាច្រើន តែងកើតមាន ពាក់ព័ន្ធនឹងការបង្កើតវិធីសាស្ត្រ ដើម្បីធានាថា ភ្នាក់ងារប្រឆាំងអំពើពុករលួយ ទាំងអស់នៅក្នុងប្រទេសអូស្ត្រាលី មានសិទ្ធិអំណាចស្មើគ្នា និងអាចកាត់ទោសជនដែលប្រព្រឹត្តអំពើ-ពុករលួយបាន។[23]

ដើម្បីដោះស្រាយបញ្ហាទាំងនេះ រដ្ឋាភិបាលថ្នាក់រដ្ឋមួយចំនួន បានអនុវត្តប្រព័ន្ធសុចរិតភាពជាតិរបស់អង្គការតម្លាភាពអន្តរជាតិ (Transparency International's National Integrity System)[j] ដូចជារដ្ឋ Queensland នៅឆ្នាំ២០០៩, រដ្ឋ Victoria នៅឆ្នាំ២០១០ និងរដ្ឋ South Australia នៅឆ្នាំ២០១២។[23]

## ៤. សេចក្ដីសន្និដ្ឋាន

សរុបសេចក្ដីមក ប្រទេសចិន ជាប្រទេសដែលមានអំពើពុករលួយខ្ពស់ ខណៈពេលដែលប្រទេសអូស្ត្រាលី គឺជាប្រទេសមួយ ក្នុងចំណោមប្រទេស ដែលមានអំពើពុករលួយទាប នៅលើពិភពលោក។ ទោះបីជាមានភាពខុសគ្នាយ៉ាងនេះក្ដី ក៏ប្រទេសទាំងពីរ បានបង្កើតភ្នាក់ងារប្រឆាំងអំពើពុករលួយមួយចំនួន ក្នុងគោលបំណងដូចគ្នា គឺដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ។ ដូចគ្នានេះផងដែរ ប្រទេសទាំងពីរ បានបង្កើតក្របខ័ណ្ឌច្បាប់ និងយន្តការពាក់ព័ន្ធ ដែលច្បាប់ប្រឆាំងអំពើពុករលួយភាគច្រើន មាននៅក្នុងក្រមព្រហ្មទណ្ឌ។ តាមរយៈដំណើរការនៃប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ ការប្រឆាំងអំពើពុករលួយនៅថ្នាក់មូលដ្ឋាន ទាំងនៅក្នុងប្រទេសចិន និងប្រទេសអូស្ត្រាលី មិនទាន់ទទួលបានជោគជ័យទាំងស្រុងនោះទេ ដោយសារតែមានបញ្ហាប្រឈមមួយចំនួន ដូចជានិយមន័យមិនច្បាស់របស់អំពើពុករលួយជាដើម។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលថ្នាក់ជាតិរបស់ប្រទេសទាំងពីរ នៅតែប្ដេជ្ញាចិត្តប្រឆាំងអំពើពុករលួយ នៅក្នុងប្រទេសរបស់ខ្លួន។

---

[j] ការវាយតម្លៃប្រព័ន្ធសុចរិតភាពជាតិ (National Integrity System) ពិនិត្យទាំងទៅលើក្របខ័ណ្ឌជាផ្លូវការ និងការអនុវត្តជាក់ស្ដែងរបស់ស្ថាប័ន។ ការវិភាគនេះ សង្កត់ធ្ងន់ទៅលើភាពខុសគ្នារវាងបទប្បញ្ញត្តិ និងការពិតជាក់ស្ដែង ដោយបង្ហាញច្បាស់ពីចំណុច ដែលត្រូវកែលម្អឲ្យល្អប្រសើរជាងមុន។

# គន្ថនិទ្ទេស


1. ODD-HELGE, F. (2003). Decentralization and corruption (a review of the literature).
2. NANCY, Q. & JAYA, W. (2015). The Impact of Xi Jinping's Anti-corruption Campaign on Luxury Imports in China.
3. BOLIANG, Z. (2014). MNCs, Rents and Corruption: Evidence from China.
4. ANDREW, W. (2004). The Intensification of Corruption in China.
5. BIN, D. & BENNO, T. Causes of corruption: evidence from China.
6. TRANSPARENCY INTERNATIONAL ORGANIZATION. *Corruption Perceptions Index 2016* [Online]. Available: http://www.transparency.org/news/feature/corruption_perceptions_index_2016.
7. HERBERT SMITH, L. (2011). Guide to anti-corruption regulation in Asia.
8. ROBERTA, R. & RONALD, W. (2015). Decentralisation and Subsidiarity: Concepts and frameworks for emerging economies.
9. MAYLING, B. (2013). Decentralization and veiled corruption under China's "rule of mandates"
10. CHUNLI, S., JING, J. & HENG-FU, Z. (2012). Fiscal Decentralization in China: History, Impact, Challenges and Next Steps.
11. JIRO, N. (2015). China's Fiscal Position and Policy: Current Status of Local Government Debt Problems and Challenges.
12. JIAHONG, H. (2016). Reorganization of anti-corruption agencies in China.
13. JEREMY, W. (2015). The New Normal: Reform, Information, and China's Anti-Corruption Crusade in Context.
14. Criminal Law of the People's Republic of China.
15. Eight Amendment to the Criminal Law of the People's Republic of China.
16. CLIFFORD CHANCE (2015). Recent trends in anti-corruption enforcement in China.
17. MARY, S. (2016). Chinese Gift-Giving, Anti-corruption Law, and the Rule of Law and Virtue.
18. CLIFFORD CHANCE'S ASIA PACIFIC ANTI-CORRUPTION GROUP (2014). A Guide to Anti-corruption legislation in Asia Pacific 2014.
19. Anti-unfair Competition Law of the People's Republic of China.
20. Law of the People's Republic of China Against Unfair Competitionm.
21. PALMINA, M. F., ANANDA, M. & HENRY, L. (2013). China: 2013 Guidance on PRC Anti-Bribery Law Focuses on Bribe Givers.
22. SIMON, B. (2013). Policing corruption and corporations in Australia: Towards a new national agenda.
23. TRANSPARENCY INTERNATIONAL ORGANIZATION (2016). Anti-corruption Agencies in Australia.
24. AUSTRALIAN GOVERNMENT. Available: http://www.australia.gov.au/about-government/how-government-works/federation

http://www.australia.gov.au/about-government/how-government-works/local-government.

25. AUSTRALIAN GOVERNMENT (2014-2015). Local Government National Report. *In:* DEVELOPMENT, D. O. I. A. R. (ed.).
26. AUSTRALIAN COLLABORATION (2015). Democracy in Australia - Corruption
27. Criminal Code Act 1995. Division 70.
28. COMMONWEALTH CONSOLIDATED ACTS Crime Act 1914, Section 15GE.
29. ROBERT R, W. (2010). International Serious and Organised Crime Conference 2010: Anti-corruption Regulation in Australia - Myth or Reality?
30. GOWRI, K. (2015). Definition of corrupt conduct: The High Court has limited the scope of the New South Wales Independent Commission against Corruption's powers.